ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០២ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១១

## សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រកាសផ្សព្វផ្សាយព័ត៌មានលទ្ធកម្មសាធារណៈ តាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមប្រកាសជូនដំណឹងដល់សាធារណជន ជាពិសេសអ្នកដេញថ្លៃទាំងអស់មេត្តាជ្រាបថា ដើម្បីបង្កើននូវភាពយុត្តិធម៌ តម្លាភាព ប្រសិទ្ធភាព ការសន្សំសំចៃខ្ពស់ក្នុងការដេញថ្លៃរាល់គម្រោងសាធារណៈ ស្របតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការផ្សព្វផ្សាយព័ត៌មានលទ្ធកម្មសាធារណៈ ជាពិសេសការប្រកាសផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃជាសាធារណៈតាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.mef.gov.kh/procurement បន្ថែមលើការផ្សព្វផ្សាយតាមរយៈសារព័ត៌មាន វិទ្យុ ទូរទស្សន៍ និងកញ្ចប់ព័ត៌មាន ដែលក្រសួងធ្វើឡើងដោយកត្តាក៏នអនុវត្តលទ្ធកម្មនាពេលកន្លងមក ។

សម្រាប់ជំហានដំបូង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការប្រកាសផ្សព្វផ្សាយតែអំពីការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក និងការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិប៉ុណ្ណោះ ។ រីឯការប្រកាសផ្សព្វផ្សាយអំពីការពិគ្រោះថ្លៃ ការស្ទង់តម្លៃ និងព័ត៌មានលទ្ធកម្មសាធារណៈផ្សេងៗទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងជូនដំណឹងនៅពេលក្រោយ ។

ការផ្សព្វផ្សាយព័ត៌មានលទ្ធកម្មសាធារណៈតាមរយៈគេហទំព័រ www.mef.gov.kh/procurement នេះនឹងត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ នេះតទៅ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបតាមការគួរ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_admin@yahoo.com